ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែកុម្ភៈ ឆ្នាំ២០២៤

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៤នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

១.១-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

១.១.១-បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ

-បានអនុញ្ញាតឱ្យលោកជំទាវបណ្ឌិត **សឿង រដ្ឋចាវី** ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាទើបតែងតាំងថ្មី ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍ មុនពេលអញ្ជើញទៅបំពេញបេសកកម្មការទូតប្រចាំនៅសាធារណរដ្ឋប្រជាមានិតចិន នៅវិមានព្រឹទ្ធសភា។

១.១.២-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខ សមាជិក សមាជិកាក្រុមប្រឹក្សាសង្កាត់ ចំនួន០៤លើក នៅខណ្ឌសែនសុខ ខណ្ឌបឹងកេងកង ខណ្ឌច្បារអំពៅ និងខណ្ឌដូនពេញ រាជធានីភ្នំពេញ។

១.១.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញសាកសួរសុខទុក្ខពីព្រះរាជសុខភាព និងនាំយកទេយ្យវត្ថុថ្វាយសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះគ្រូចៅអធិការវត្តបទុមវតី នៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមពិធីបុណ្យគម្រប់១ឆ្នាំ និងឆ្លងប្រាង្គព្រះចេតិយឧទ្ទិសកុសលដល់ដួងវិញ្ញាណក្ខន្ធ លោកជំទាវមហាសទ្ធាភិរ័ក្ខធម្មសិរីរតន៍ អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ប៊ុន សុថា** ដែលត្រូវជាប្អូនថ្លៃ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមបុណ្យខួប១០០ថ្ងៃ ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធ មហាឧបាសិកា



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ពុទ្ធសាសនូបត្ថម្ភក៏ **យិប ចាំកេសន** ដែលត្រូវជាម្ដាយក្មេករបស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅសង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង

-បានអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសពមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **មុជ សុគ្គុន** ម្ដាយបង្កើតឯកឧត្ដម **ហូ សិទ្ធី** ទេសរដ្ឋមន្ត្រី និងជានាយកខុទ្ទកាល័យសម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅវត្តក្រពើហា ផ្លូវជាតិលេខ២ សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល។

១.១.៤-ពិនិត្យ និងផ្ដល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន០៦ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៥៣ច្បាប់។

**១.២-ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ព្រឹទ្ធសភា**

១.២.១-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញថ្វាយបង្គំព្រះគ្រូចៅអធិការវត្ត និងជួបសំណេះសំណាលជាមួយគណៈកម្មការអាចារ្យវត្ត ដើម្បីពិភាក្សាអំពីការកំណត់កាលបរិច្ឆេទរៀបចំចាត់ចែងពិធីបុណ្យឆ្លងសមិទ្ធផលដែលបានកសាងកន្លងមកនៅវត្តទេពនិម្មិត ហៅវត្តអញ្ចាញ ស្ថិតនៅឃុំក្របៅ ស្រុកកំចាយមារ និងជួបពិភាក្សាអំពីការជួសជុលដំបូលវិហារសារជាថ្មីជាមួយព្រះគ្រូចៅអធិការវត្ត គណៈកម្មការអាចារ្យវត្ត នៅវត្តពង្សរង្សី ហៅវត្តជ្រៃម្រាក់ ស្ថិតនៅឃុំគោកគង់កើត ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។

១.២.២-ពិនិត្យ និងផ្ដល់យោបល់លើឯកសារផ្សេងៗ

-បានទទួលឯកសារជ្រាបជាព័ត៌មាន ចំនួន២៧ច្បាប់។

**១.៣-ឯកឧត្ដមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា**

១.៣.១-សកម្មភាពចុះមូលដ្ឋាន

-បានចាត់ឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ។

១.៣.២-ពិនិត្យ និងផ្ដល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន១៣ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៣០ច្បាប់។

## ២-គណៈកម្មការនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភាបានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

## ២.១-មុខងារតំណាង

-បានទទួលពាក្យបណ្ដឹងចំនួន០១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន០១ករណី បានបញ្ជូនពាក្យបណ្ដឹង ទៅក្រសួង និងស្ថាប័នពាក់ព័ន្ធចំនួន០១ករណី កំពុងពិនិត្យសិក្សាចំនួន ០៣ករណី តម្កល់ទុកមិនចាត់ការចំនួន០២ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន០៣ករណី បានទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន០២ករណី

-បានអញ្ជើញចូលរួមប្រជុំពិភាក្សា ដើម្បីផ្ដល់ធាតុចូលលើការឆ្លើយកម្រងសំនួរនៃការអង្កេតលើការបើកចំហថវិកា ក្រោមអធិបតីភាពឯកឧត្ដម **ឈាង វុន** ប្រធានគណៈកម្មការទី២ រដ្ឋសភា នៅវិមានរដ្ឋសភា

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា០១ខ្នង មាន៦បន្ទប់ នៅសាលាបឋមសិក្សាវាលនិន្ទ្រា ក្រោមអធិបតីភាពលោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ប៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា នៅសាលាបឋមសិក្សាវាលនិន្ទ្រា ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់

-បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយអ្នកវិនិយោគិនជាតិ អញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់ និងការវិនិយោគលើវិស័យកសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ក្នុងគោលបំណងចង់បង្កើតការងារជូនប្រជាពលរដ្ឋ នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

-បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយ លោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមប្រជុំជាមួយក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ទីរនានាជុំវិញខេត្ត កងកម្លាំង គណៈអភិបាលស្រុក ក្រុង ក្រុមប្រឹក្សាស្រុក ក្រុង ឃុំ សង្កាត់ និងមេភូមិគ្រប់ភូមិទូទាំងខេត្តឧត្តរមានជ័យ

-បានអញ្ជើញធ្វើបទបង្ហាញដល់និស្សិត និងសាស្ត្រាចារ្យ មកពីសាកលវិទ្យាល័យឯកទេសនៃកម្ពុជា នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន០៣លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រួមមានៈ ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ " កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ", ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងព័ត៌មាន, ពិធីប្រកាសទទួលស្គាល់ជ័យលាភីអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលឆ្នាំ២០២៣ និងប្រកាសដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាក-សួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយនានា ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន ២៣០លើក ព្រមទាំងបានអញ្ជើញជាគណៈអធិបតី ក្នុងពិធីសម្ពោធសមិទ្ធផលនានា និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៤៣លើក។

**២.២-កិច្ចសហប្រតិបត្តិការអន្តរជាតិ**

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោមៈ

-បានអញ្ជើញជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះចៅអធិរាជជប៉ុន ដែលរៀបចំដោយលោកVENO Atsushi ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅស្ថានទូតជប៉ុន រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាកិត្តិយសអបអរសាទរទិវាបុណ្យជាតិអូស្ត្រាលី ឆ្នាំ២០២៤ នៅស្ថានទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញជាកិត្តិយសក្នុងពិធីបុណ្យជប៉ុន-កម្ពុជា គីហ្សូណា ឆ្នាំ២០២៤ ដែលរៀបចំដោយស្ថានទូតជប៉ុន សហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) និងមូលនិធិជប៉ុន ស្ថិតនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ថ្ងៃ ចន្ទ ៩ រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០២៤

**ជ.ប្រធានស្តីទីព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
  (ជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ